# ធម្មកថា

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ អំពីការចូលព្រះវស្សារបស់ព្រះភិក្ខុសង្ឃ ក្នុងព្រះពុទ្ធសាសនា

web site: hoksavann.org

ថ្ងៃទី២៦ មិថុនា ២០០៥

រដូវវស្សាជារដូវភ្លៀង ព្រះភិក្ខុសង្ឃពិបាកធ្វើដំណើរពីកន្លែងមួយទៅកន្លែងមួយ ទើបព្រះពុទ្ធមានពុទ្ធានុញ្ញាតឲ្យភិក្ខុសង្ឃនៅចាំព្រះវស្សានៅទីវត្តណាមួយ ដើម្បីរៀនសូត្រធម៌វិន័យនិងអប់រំចិត្ត ហើយងាយស្រួលឲ្យពុទ្ធបរិស័ទទំនុកបំរុងដោយបច្ច័យបួនផង ។ កន្លែងខ្លះនិយាយថា រដូវវស្សាជារដូវធ្វើស្រែចំការ ព្រះភិក្ខុសង្ឃនិមន្តចុះឡើង តែងតែជាន់សន្ទូងរបស់គេ ដោយមានការរិះគន់ពីអ្នកស្រែចំការ ទើបព្រះអង្គមានពុទ្ធានុញ្ញាតឲ្យភិក្ខុសង្ឃចាំវស្សារហូតដល់ចប់រដូវភ្លៀង ។ បើយកន័យនេះជាគោល ការចាំព្រះវស្សាកន្លែងដទៃទៀត ដែលគ្មានធ្វើស្រែចំការ ពុំចាំបាច់ចូលវស្សាទេ ។ ដូច្នេះ គួរសំអាងតាមគោលខាងដើមទើបសមរម្យជាង គឺរដូវភ្លៀងព្រះភិក្ខុសង្ឃពិបាកធ្វើដំណើររកបច្ច័យបួន មានពិបាកក្នុងការនិមន្តបិណ្ឌបាត្រជាដើម ហើយបើនៅស្រុកស្រែចំការផង អ្នកស្រុកចេញទៅធ្វើការតាំងពីព្រលឹម ពុំអាចមានពេលដាក់បាត្រតាមពេលវេលាបាន ដូច្នេះបើព្រះសង្ឃចាំវស្សាមួយកន្លែង គេស្រណុកដាក់វេនគ្នាមួយក្រុមម្តងៗ ប្រគេនចង្ហាន់ចំពោះព្រះសង្ឃរហូតចេញព្រះវស្សា ព្រោះព្រះសង្ឃជំនាន់ពុទ្ធកាល ពុំសូវគង់នៅមួយកន្លែង ច្រើនធ្វើសំណើរពីកន្លែងមួយទៅកន្លែងមួយ ។ បន្ទាប់ពីមានពុទ្ធានុញ្ញាតមក ការចូលព្រះវស្សាជាកិច្ចមួយចាំបាច់របស់ព្រះភិក្ខុសង្ឃរៀងរាល់ឆ្នាំ ហើយជាឱកាសឲ្យព្រះសង្ឃសិក្សារៀនសូត្រធម៌វិន័យ និងចំរើនសមថៈនិងវិបស្សនា ។ ភិក្ខុសង្ឃត្រូវចាំវស្សានៅវត្តណាមួយចំនួន៣ខែ ចាប់តាំងពីថ្ងៃ១រោជខែអាសាធ បើខែមានអធិកមាសលើកខែ ត្រូវចូលទៅខែទុតិយាសាធ ។ ឯសាមណេរ ទោះបីគ្មានចែងក្នុងព្រះវិន័យថាឲ្យចាំវស្សា ក៏ត្រូវចូលវស្សាជាមួយព្រះភិក្ខុសង្ឃដែរ ។ ចំណែកឧបាសក

ឧបាសិកាជាគ្រហស្ថ ដែលមានសទ្ធាជ្រះថ្លាកាន់សីល៨, សីល១០ ឬធ្វើបាដិហារិយឧបោសថ ក៏អាចចូលវស្សាជំណាលគ្នានឹងភិក្ខុសង្ឃដែរ ដើម្បីបំពេញកិច្ចជាកុសលនេះ ។ សូម្បីសត្វបក្សាបក្សីនិងសត្វល្អិតជំពូកខ្លះ នៅសម្ងំមួយកន្លែងនៅរដូវភ្លៀងដែរ ដោយវាសន្សំស្បៀងទុកជាមុន ។

នៅយប់ថ្ងៃ១៥កើតខែបឋមាសាឍ ឬខែទុតិយាសាឍ មុនចូលព្រះវស្សាមួយថ្ងៃ ពុទ្ធបរិស័ទបាននាំគ្នាទៅវត្តរួមអនុមោទនាជាមួយព្រះភិក្ខុសង្ឃដែលចូលព្រះវស្សា មានការហែទៀនព្រះវស្សា ស្តាប់ព្រះសង្ឃចំរើនព្រះបរិត្តនិងស្តាប់ទេសនា ។ នៅស្រុកស្រែចំការ ដែលគ្មានភ្លើងអគ្គីសនី គេទិញប្រេងកាតប្រគេនព្រះសង្ឃទុកសំរាប់អុជបំភ្លឺ ក្នុងការសិក្សារៀនសូត្រនៅពេលយប់ ។ នៅពេលនោះ, គេប្រគេនគ្រឿងបរិក្ខារជាបច្ច័យ៤ មានសំពត់សាដក ឬសំពត់ងូតទឹកភ្លៀងជាដើម សំរាប់ទំនុកបំរុងព្រះសង្ឃក្នុងពេលចូលព្រះវស្សា ។ លុះព្រឹកឡើងថ្ងៃ១រោច គេធ្វើពិធីរាប់បាត្រ វេរចង្ហាន់ប្រគេនព្រះសង្ឃ លុះដល់ពេលយប់នៃថ្ងៃដដែល ទើបព្រះភិក្ខុ និងសាមណេរសូត្រកំណត់ចូលព្រះវស្សា ។

ក្នុងរយៈកាល៣ខែអំឡុងចូលព្រះវស្សានោះ វត្តខ្លះមានពុទ្ធបរិស័ទទៅសិក្សារៀនសូត្រព្រះពុទ្ធសាសនា និងអប់រំចិត្តតាមវិធីសមថៈនិងវិបស្សនាកម្មដ្ឋាន និងដាក់វេនចង្ហាន់ប្រគេនព្រះសង្ឃ ។ ចំណែកព្រះសង្ឃក៏មានកម្មវិធីសិក្សាធម៌វិន័យ និងអប់រំចិត្ត ។ រយៈពេលចូលព្រះវស្សានេះ បើមានកិច្ចដូចជាទៅជួយរម្ងាប់អធិករណ៍របស់ភិក្ខុសង្ឃក្នុងវត្តណាមួយដែលបំរុងបែកគ្នា ទៅថ្វាយបង្គំព្រះឧបជ្ឈាយ៍, ទៅសួរសុខទុក្ខមាតាបិតាដែលជាញោម គេនិមន្តទៅទេសនា ទៅទទួលភត្តជាដើម ព្រះភិក្ខុសង្ឃអាចចេញពីវត្តបានចំនួន៧ថ្ងៃនិង៦រាត្រី ដោយត្រឡប់មកវត្តវិញឲ្យភ្លឺនៅវត្តដើមវិញនៅយប់ថ្ងៃទី៧ ហៅថាលើកសត្តាហៈ ។ ព្រះសង្ឃដែលបានចាំវស្សាគ្រប់ត្រៃមាស គឺគ្រប់៣ខែ អាចទទួលក្រាលគ្រងនិងអនុមោទនាកឋិនបាន ដោយអានិសង្សនៃការចូលវស្សានេះ ។ ម្យ៉ាងទៀត ការចូលវស្សានេះមានប្រយោជន៍ជាពិសេសដល់ភិក្ខុសាមណេរ ក្នុងការសិក្សាលើគ្នាទៅវិញទៅមក នូវធម៌វិន័យ ហើយជួយរិះគន់គ្នាទៅវិញទៅមក ក្នុងន័យស្ថាបនានូវទោសកំហុសខុសឆ្គង ហើយកែលំអឲ្យត្រូវតាមធម៌វិន័យវិញ ។

ប្រៀបមកផ្លូវអាណាចក្រវិញ គ្រួសារមួយឬសង្គមមួយ ដែលអាចរស់នៅជាមួយគ្នាបាន លុះត្រាតែស្ថិតនៅក្រោមអំណាចច្បាប់មួយ ដែលត្រូវគោរពទាំងអស់គ្នា បើមានការខុសឆ្គងបន្តិចបន្តួច គួរមានអធ្យាស្រ័យអត់ឱនឲ្យដល់គ្នាទៅវិញទៅមក ប្រកបដោយមេត្តាធម៌ ជារបៀបមានសុជីវធម៌ ។ តាមធម្មតាបើមានការរំលោភច្បាប់ប្រទេសដ៏ធ្ងន់ ទើបធ្វើតាមកំហុស ក៏ដូចគ្នានឹងព្រះសង្ឃ បើមានកំហុសក្នុងព្រះវិន័យ ក៏ធ្វើតាមកំហុសដែរ ។ ពិភពលោកសព្វថ្ងៃនេះ គេខ្លាចបំផុតត្រង់អ្នកមានអំណាចរំលោភលើសិទ្ធិប្រជាពលរដ្ឋ គឺយកអំណាចដែលប្រជាពលរដ្ឋប្រគ-

ល់ឲ្យ ទៅបៀតបៀនសង្កត់សង្កិនជិះជាន់ប្រជាពលរដ្ឋរបស់ខ្លួន ដែលមានលក្ខណៈជាអំពើផ្តាច់ការ ។ ចំណែកព្រះសង្ឃព្រះពុទ្ធសាសនារស់នៅជាមួយគ្នាយ៉ាងសុខស្រួល ដោយគោរពតាមព្រះវិន័យ ដែលព្រះអង្គបញ្ញត្តិមកដូចគ្នា ជាពិសេសរស់នៅបានសុខស្រួលក្នុងរយៈកាល៣ខែក្នុងអំឡុងចូលព្រះវស្សានេះឯង ។៚

⌘ ⌘

⌘